**TTB0013**

**សេចក្តីផ្តើម៖** អស់លោកលោកស្រី និងបងប្អូនស្ងួនភ្ងារជាទីស្រឡាញ់ក្នុងព្រះអម្ចាស់ព្រះយេស៊ូវ នៅក្នុងវគ្គសិក្សាកន្លងទៅ យើងបានសិក្សាពីសេចក្តីពិតនានាដូចបានសំដែងនៅក្នុងព្រះគម្ពីរប៊ីបរួចមកហើយ។ នៅក្នុងមេរៀនក្នុងថ្ងៃនេះយើងខ្ញុំសូមអញ្ជើញលោកអ្នក ឲ្យបានសិក្សាពីលក្ខណៈផែនដីចាស់ដែលត្រូវទទួលគ្រោះមហន្តរាយមួយយ៉ាងធំ ព្រះជាម្ចាស់បានសូនផែនដីឲ្យមានដូចជាផែនដីដែលយើងរស់នៅសព្វថ្ងៃ។ តើព្រះជាម្ចាស់បង្កើតផែនដីក្នុងរយៈពេលប៉ុន្មានថ្ងៃ? តើថ្ងៃនីមួយៗព្រះជាម្ចាស់បានបង្កើតអ្វីខ្លះ? អស់លោកអ្នកបងប្អូនសូមបានត្រៀមប៉ាកានិងសៀវភៅ ដើម្បីកត់ចំណាំនូវចំណុចសំខាន់ៗ។ សូមចូលរួមសណ្តាប់ជាមួយនិងការបកស្រាយដូចតទៅ....

ព្រះជាម្ចាស់បានប្រទានដល់យើងអោយឃើញ នូវគោលការណ៍ធំៗសំខាន់ៗនៅក្នុងខមួយនិងខពីរជំពូក១នៃព្រះគម្ពីរលោកុប្បត្តិនេះ។

> **ឯផែនដីបានខូចហើយនៅទទេ មានសុទ្ធតែងងឹតនៅគ្របលើជំរៅទឹក ហើយព្រះវិញ្ញាណនៃព្រះក៏រេរា នៅពីលើទឹក (លោកុប្បត្តិ ១០:២)។**

ខ្ញុំយល់ឃើញថាមានហេតុការណ៍អាក្រក់មួយកើតឡើងនៅចន្លោះខ (១-២)។ ខ្ញុំហ៊ានអះអាងបែបនេះព្រោះមានភ័ស្តុតាង ច្រើនណាស់គាំទ្រការសន្និដ្ឋាននេះ។ ដើម្បីឈានចូលទៅពិភាក្សាហេតុការណ៍ដែលកើតឡើងចន្លោះខ១ និងខ២សូមយើងសង្កេត

មើលអំពីភាពល្អល្ហេវដូចជាទីរហោស្ថានដែលកើតមាននៅលើលោកយើងនេះ។ ភាពល្អល្ហេវនៃទីរហោស្ថានទាំងនោះ សបញ្ជាក់ថា នៅលើលោកសន្និវាសយើងនេះច្បាស់ជាមានហេតុការណ៍អ្វីមួយអាក្រក់កើតឡើងនៅក្នុងអតីតកាលជាមិនខាន។ ពេលដែលមនុស្សលោកបានឈានឡើងទៅ ដល់ឋានព្រះនន្ទ្រមុនដំបូងបង្អស់គេមិនបានរកឃើញថា មានអ្វីកើតនៅទីនោះក្រៅពីភាពសោះកក្រោះជាទីបំផុតនោះទេ។ ហេតុអ្វីបានជាដីមានភាពសោះកក្រោះនៅលើពិភពព្រះចន្ទ្រ? ខ្ញុំសន្និដ្ឋានថាពិតជាមានហេតុការណ៍អាក្រក់ណាមួយកើតឡើងនៅក្នុងលោកសន្និវាស ដែលព្រះជាម្ចាស់បានបង្កើតពីមុនមកជាពិតប្រាកដ។

ចុះហេតុអ្វីបានជានៅក្នុងបទគម្ពីរនេះ និយាយតែពីរឿងផែនដីទៅវិញ? ពីព្រោះផែនដីជាកន្លែងដែលមានមនុស្សរស់នៅ។ នៅក្នុងបទគម្ពីរបានចែងទុកមកថាផែនដីបានខូចហើយនៅទទេ។

ខនេះបានសម្តែងថា ងងឹតគ្របលើជំរៅទឹកដែលសបញ្ជាក់អោយឃើញថាព្រះជាម្ចាស់មិនមានវត្តមាននៅទីនេះឡើយ។ ពាក្យថា "បានខូចហើយនៅទទេ" ជាពាក្យមួយដែលគួរអោយយកចិត្តទុកដាក់បំផុត។ "បានខូច" នៅក្នុងភាសាហេព្រើរគេប្រើពាក្យ "ថូហ៊ូ" មានន័យថា ខូចឬប្រើមិនកើត។ ឯពាក្យមួយទៀត "នៅទទេ" ក្នុងភាសាហេព្រើរគេប្រើពាក្យ "បូហ៊ូ" មានន័យថា ទទេសោះតែម្តង។ សុំកត់ចំណាំថាសេចក្តីនេះមានចែងទុកនៅក្នុងបទទំនាយ ព្រះគម្ពីរអេសាយផងដែរ "ដ្បិតព្រះយេហូវ៉ាដែលបានបង្កើតផ្ទៃមេឃ ជាព្រះដែលទ្រង់សូនធ្វើ ហើយប្រតិស្ឋានផែនដី ក៏តាំងឡើងមិនមែនបង្កើតមកអោយនៅទទេទេ គឺបានជប់សូនបង្កើតអោយជាទីអាស្រ័យនៅ

(អេសាយ ៤៥ៈ១៨ )។ នៅត្រង់បទគម្ពីនេះព្រះជាម្ចាស់ចង់មានបន្ទូលថា៖ "ទ្រង់មិនបានបង្កើតផែនដីនេះមកអោយនៅទទេ ឯភាសាទទេនៅក្នុងឃ្លានេះគឺប្រើជាភាសាហេព្រើរ "ថូហ៊ូ" ដែលមានប្រើដូចគ្នានៅក្នុងព្រះគម្ពីរលោកុប្បត្តិ១ៈ២នេះដែរ។ ព្រះជាម្ចាស់មិនបានបង្កើតពិភពលោក មកដើម្បីអោយខូចឬនៅទទេនោះឡើយ។ ព្រះជាម្ចាស់បង្កើតលោកសន្និវាសនេះមក ដោយសារព្រះហស្តរបស់ទ្រង់ធ្វើអោយចេញជារូបរាងឡើង មិនមែនព្រះអង្គបង្កើតសម្រាប់អោយខូចខាតនោះទេ។ ត្រង់នេះហើយដែលហោរាអេសាយចង់បញ្ជាក់អោយបានច្បាស់លាស់ថា ព្រះជាម្ចាស់ពិតជាមិនបានបង្កើតផែនដីមកអោយខូច ឬ នៅទទេនោះដែរ។ ប៉ុន្តែ ផែនដីបានត្រឡប់ទៅជាខូចហើយនៅទទេវិញ។ ព្រះជាម្ចាស់ទ្រង់បានសូនផែនដីមកដើម្បីអោយមានមនុស្សរស់នៅ ហើយព្រះអង្គត្រូវធ្វើអោយផែនដីដែលខូចនោះអោយត្រឡប់ទៅជាកន្លែងដែលមនុស្សអាចរស់បានដូចទ្រង់ប្រៀងទុក។

បើតាមការសិក្សាស្រាវជ្រាវរបស់មនុស្សបច្ចុប្បន្ននេះ នៅក្នុងអវកាសអ្នកប្រាជ្ញបានរកឃើញថា មានតែផែនដីមួយកន្លែងប៉ុណ្ណោះនៅលើលោកសន្និវាសនេះដែលមនុស្សអាចរស់នៅបាន។ ប៉ុន្តែ ខ្ញុំជឿលើព្រះគម្ពីរលោកុប្បត្តិដែលសម្តែងប្រាប់យើងថា ផែនដីក្លាយទៅជាទទេនិងខូចផង ពោលគឺមានកន្លែងដែលមិនអាចរស់នៅកើតជាតួយ៉ាងដូចជាឋានព្រះចន្ទ្រជាដើម។ ការនោះកើតឡើងមុនពេលព្រះវិញ្ញាណនៃព្រះបានយាងមកលើផ្ទៃទឹក ។

ខ្ញុំផ្ទាល់មានជំនឿថា លោកសន្និវាសយើងនេះធ្លាប់បានជួបនឹងគ្រោះមហន្តរាយមួយយ៉ាងធំ។ តើគ្រោះមហន្តរាយនោះជាអ្វីទៅ? យើងមិនអាចដឹងបាន

ច្បាស់ទេ គ្រាន់តែអាចសន្និដ្ឋានបានថា ពិតជាមានភាវៈអ្វីមួយស្នាក់នៅលើលោកនេះ មុនពេលព្រះជាម្ចាស់បង្កើតអ័ដាមមក។ ក្នុងការសន្និដ្ឋាននេះយើងមើលទៅហាក់ដូច ជាមានការទាក់ទងជាមួយនឹងមហាទេវតាមួយរូបឈ្មោះ លូស៊ីហ្វឺរ ដែលព្រះជាម្ចាស់ បានបណ្តេញចុះពីស្ថានសួគ៌មក ហើយឥឡូវនេះយើងហៅថាសាតាំងឬក៏មេអារក្សដូច យើងស្គាល់សព្វថ្ងៃនេះ។ ខ្ញុំគិតថាហេតុការណ៍ដែលកើតឡើងក្នុងពេលនោះគឺដូច្នេះឯង ប៉ុន្តែព្រះជាម្ចាស់មិនបានប្រទានអោយយើងដឹងជាពិស្តារឡើយ។ តាមពិតរឿងនេះព្រះ អង្គមិនបានអោយយើងដឹងល្អិតល្អន់ទេ គឺទ្រង់គ្រាន់តែបំភ្លឺអោយឃើញជាហេតុៗ ប៉ុណ្ណោះ នៅក្នុងជំពូក១នៃគម្ពីរលោកុប្បត្តិនេះ។

“ហើយព្រះវិញ្ញាណនៃព្រះក៏រេរា”។ ពាក្យថារេរាមានន័យថា ហោះពីលើ ដោយបបោសអង្អែល ប្រៀបដូចជាមេមាន់ដែលក្រាបពីលើហ្វូងកូនមាន់ដែរ។ ព្រះអម្ចាស់ទ្រង់ហោះពីលើផ្ទៃទឹក។ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការនេះ ហើយទ្រង់បាន ធ្វើហើយធ្វើទៀតគឺព្រះអង្គរេរានៅលើផ្ទៃទឹក។ សកម្មភាពនេះគឺជាការបង្កើតផែនដី សារជាថ្មី។ ទ្រង់បានបើកសម្តែងអង្គទ្រង់អោយឃើញនូវឆាកកកើតលោកនេះ ហើយ ទ្រង់ក៏បានបង្កើតលោកនេះសារជាថ្មីឡើង។

សុំអោយលោកអ្នកបងប្អូន នឹកចាំពីព្រះបន្ទូលរបស់ព្រះអម្ចាស់ព្រះយេស៊ូវ គ្រីស្ទដែលទ្រង់មានបន្ទូលនៅក្នុងព្រះគម្ពីរយ៉ូហានដែលបានចែងយ៉ាងដូច្នេះថា “ប្រាកដ មែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណនោះគ្មាន អ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ” (យ៉ូហាន ៣:៥)។ ទឹកគឺជីព្រះបន្ទូលរបស់ ព្រះជាម្ចាស់។

ឥឡូវនេះបើលោកអ្នកបងប្អូនចង់ពន្យល់ថាទឹកជានិមិត្តរូបនៃការធ្វើបុណ្យជ្រមុជទឹកគឺអាចនិយាយបាន ប៉ុន្តែន័យពិតប្រាកដនៃទឹកត្រង់នេះមានន័យថាព្រះព្រះបន្ទូលរបស់ព្រះជាម្ចាស់តែម្តង។ រីឯព្រះវិញ្ញាណនៃព្រះក៏ជាអង្គដែលនិពន្ធបទគម្ពីរទាំងមូលនេះមក។

## ការស្ថាបនាផែនដីឡើង

នៅក្នុងខ១យើងឃើញអំពីការស្ថាបនាលោកសន្និវាស រីឯខ២វិញយើងឃើញមានគ្រោះមហន្តរាយកើតឡើងលើផែនដីនេះ។ ឥឡូវនេះសុំលោកអ្នកបងប្អូនកត់ចំណាំម្តងទៀតពីការស្ថាបនាផែនដី នេះឡើងនៅក្នុងរយៈពេល៦ថ្ងៃ (ខ៣-៣១ )។ ត្រង់នេះខ្ញុំជឿថា មានការកើនឡើងនៃការបង្កើតលោកយើងនេះ។

មានហេតុការណ៍ជាច្រើននៅទីនេះ ដែលខ្ញុំចង់អោយលោកអ្នកយកចិត្តទុកដាក់អោយបានច្បាស់លាស់ជាទីបំផុត។ ព្រះគម្ពីរនិក្ខមនំ បានចែងថា "ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានធ្វើផ្ទៃមេឃផែនដី ហើយនិងសមុទ្រព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ។ រួចដល់ថ្ងៃទី៧ទ្រង់ឈប់សម្រាក ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សម្រាក ហើយញែកចេញជាបរិសុទ្ធ" (និក្ខមនំ២០ៈ១១)។ បើយើងសង្កេតមើលកិរិយាសព្ទនៅក្នុងខនេះយើងមិនបានឃើញពាក្យ"បង្កើត"ទេ។ ប៉ុន្តែព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាទ្រង់ "ធ្វើ" វិញ។ ព្រះជាម្ចាស់បានធ្វើរបស់ដែលកើតរួចមក ដោយយកមកសូនធ្វើសារជាថ្មីក្នុងរយៈពេល៦ថ្ងៃ។ ព្រះអម្ចាស់បានធ្វើរបស់ទាំងនោះ ពីព្រោះរបស់ទាំងនោះមានរួចមកហើយ ពោលគឺរបស់ដែលព្រះ

អង្គបង្កើតប្រហែលជារាប់លានឆ្នាំកន្លងទៅ។ ព្រះជាម្ចាស់បានបង្កើតអោយមានជីវិត ហើយទុកអោយជីវិតនោះមាននៅ លើផែនដីដែលទ្រង់ជាព្រះបានបង្កើតអោយមានមនុស្សលោកឡើង។ មនុស្សលោកនេះគឺជាភាវៈមួយដែលយើងទាំងអស់គ្នាយកចិត្តទុកដាក់ជាទីបំផុត។ ព្រោះលោកអ្នកនិងខ្ញុំជាភាវៈមួយក្នុងចំណោមភាវៈរាប់លានទៀតដែលព្រះជាម្ចាស់ទ្រង់បានបង្កើតមក។ ដូច្នេះហើយបានជាព្រះជាម្ចាស់យករឿងនេះកត់ទុកក្នុងព្រះគម្ពីរលោកុប្បត្តិនេះ។

ថ្ងៃទី១ ពន្លឺ

**នោះព្រះទ្រង់មានបន្ទូលថា ចូរអោយមាន ពន្លឺឡើង ដូច្នេះពន្លឺកម៏ាន ឡើង ព្រះទ្រង់ឃើញពន្លឺនោះក៏ទ្រង់យល់ថាជាល្អហើយ រួចទ្រង់ញែកពន្លឺពីងងឹតចេញទ្រង់ហៅពន្លឺថាជាថ្ងៃ ហើយហៅងងឹតថាជាយប់ នោះក៏មាន ល្ងាច មានព្រឹកឡើងជាថ្ងៃទី១ (លោកុប្បត្តិ១០:៣-៥ )។**

ខ្ញុំយល់ថា ថ្ងៃដែលព្រះអម្ចាស់មានបន្ទូលនេះ ត្រូវជាថ្ងៃដែលមានបេរៈវេលា ២៤ម៉ោង។ សុំកត់ចំណាំពាក្យដែលព្រះអម្ចាស់ទ្រង់មានបន្ទូលបែបនេះថា"ចូរអោយមានពន្លឺ"។ ពាក្យថា"ចូរអោយមាន"នេះមានដល់ទៅ១០ដងឯណោះនៅក្នុងជំពូកមួយតែប៉ុណ្ណោះ។ ឧទាហរណ៍ដូចជា ចូរអោយមានប្រឡោះ ចូរមានទឹក ពន្លឺ បានប្រមូលគ្នានៅមួយកន្លែង។ល។ មានអ្នកខ្លះបានហៅពាក្យនេះ ថាជាក្រិត្យវិន័យទាំង១០ប្រការក្នុងការបង្កបង្កើតលោកទាំងមូល។

“ព្រះមានបន្ទូលថា ចូរអោយមានពន្លឺ”។ ត្រង់ចំណុចនេះយើងឮជាលើកដំបូងបង្អស់ហើយថា ព្រះជាម្ចាស់មានបន្ទូលមក។ ពាក្យទាំងនេះគឺជាពាក្យរបស់ព្រះដែលទ្រង់មានព្រះបន្ទូលលើកដំបូងបង្អស់ ព្រមទាំងជាពាក្យដែលបានកត់ទុកនៅក្នុងព្រះគម្ពីរផង។

## ថ្ងៃទី២ ប្រឡោះ

**បន្ទាប់មកព្រះទ្រង់មានព្រះបន្ទូលថា ចូរអោយមានប្រឡោះ នៅកណ្តាលទឹកដើម្បីញែកទឹកចេញពីគ្នា (លោកុប្បត្តិ ១០:៦ )។**

“ព្រះទ្រង់មានបន្ទូលថា ចូរអោយមានប្រឡោះ”។ ពាក្យថា "ប្រឡោះ"នេះ ជាភាសាហេព្រើរថា: "រាក់គា" មានន័យថា លំហអាកាស។

“ដើម្បីញែកទឹកចេញពីគ្នា”។ តើឃ្លានេះមានន័យយ៉ាងណាដែរ? ត្រង់នេះ ព្រះជាម្ចាស់ទ្រង់ចែកទឹកជាពីរផ្នែកដាច់ពីគ្នា។ គឺមានទឹកនៅពីលើយើងនិងមានទឹកនៅពីក្រោមយើង។

**ទ្រង់ក៏ធ្វើប្រឡោះនោះទាំងញែកទឹកដែលនៅក្រោមប្រឡោះ ចេញពីទឹកដែលនៅលើប្រឡោះក៏មានដូច្នោះ(លោកុប្បត្តិ១០:៧ )។**

នៅរៀងរាល់រដូវវស្សា យើងឃើញមានទឹកភ្លៀងធ្លាក់មកយ៉ាងច្រើន ហើយ

បើតាមមើលទៅភ្លៀងនោះ មិនមែនធ្លាក់មកពីក្រោមទេគឺធ្លាក់ពីលើមកវិញ។ យើងឃើញថាទឹកមានច្រើនណាស់នៅពីលើយើង ព្រមទាំងមានច្រើនណាស់នៅពីក្រោមយើង។ យើងសួរថា: ហេតុអ្វីបានជាមានទឹកច្រើនម្លេះនៅពីលើយើង? តើទឹកនោះដក់ដូចម្តេចកើត? ចុះដូចម្តេចបានជាមានទឹកនៅក្នុងលំហអាកាសទៅវិញ? ខ្ញុំយល់ថានេះពិតជាប្រាជ្ញាដ៏អាថ៌កំបាំងរបស់ព្រះជាម្ចាស់ដែលទ្រង់អាចធ្វើកើត។

**រួចព្រះទ្រង់ហៅប្រឡោះនោះថាជាមេឃ នោះក៏មានល្ងាចមានព្រឹកឡើងជាថ្ងៃទី២ (លោកុប្បត្តិ ១◌:៨ ) ។**

“ព្រះទ្រង់ហៅប្រឡោះនោះថាជាមេឃ”។ ពាក្យមេឃនេះមាន៣សណ្ឋាននៅក្នុងលំហអាកាសទាំងមូល។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីព្រះជាម្ចាស់មានបន្ទូលអំពីដំណើរសត្វហើរនៅលើអាកាសហើយខ្ញុំគិតថា លំហអាកាសនេះហើយ ដែលកំពុងបើកសម្តែងនៅក្នុងព្រះគម្ពីរនេះ។ មានមេឃ១ជាន់ទៀតដែលនៅទីនោះ មានផ្កាយ ព្រះចន្ទ្រ ព្រះអាទិត្យ និងចក្រវាឡ៍នានាបានតាំងនៅ។ ប៉ុន្តែ ភពដែលខ្ពស់បំផុតមួយទៀតដែលហៅថាស្ថានសួគ៌ ហើយនៅទីនោះមានព្រះជាម្ចាស់គង់នៅ។ មេឃដែលបើកសម្តែងនៅក្នុងព្រះគម្ពីរលោកុប្បត្តិនេះ ជាមេឃនៅជាន់ទាបទី១ដែលមានពពកនិងសត្វហើរលើអាកាស។

## ថ្ងៃទី៣ ដីគោកនិងរុក្ខជាតិនានា

**បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរអោយទឹកនៅក្រោមមេឃប្រមូលគ្នានៅកន្លែងតែ១ ហើយអោយមានទីគោកដុះលេចឡើង នោះក៏មានដូច្នោះទ្រង់ហៅទីគោកនោះថាជាដី ហើយទីទឹក ដែលប្រមូលគ្នានោះថា ជាសមុទ្រនោះទ្រង់ក៏ឃើញថាល្អ (លោកុប្បត្តិ១:៩-១០)។**

ឥឡូវនេះយើងឃើញថា មានទីកន្លែងដែលមានទឹកយ៉ាងសន្ធឹក។ មុនដំបូងបង្អស់ព្រះអម្ចាស់បានញែកអោយផ្ទៃទឹកមាននៅខាងលើ និងមានផ្ទៃទឹកនៅខាងក្រោមយើង។ ឥឡូវនេះទ្រង់បានញែកទឹកចេញពីទីគោកហៅថាដី។ ខ្ញុំចង់ជំរាបថា ដំណើរដែលព្រះទ្រង់មានបន្ទូលត្រង់នេះ មានភាពច្បាស់លាស់ជាងការរកឃើញរបស់ពួកវិទ្យាសាស្ត្រទៅទៀត។ ពួកអ្នកវិទ្យាសាស្ត្រគ្រាន់តែប្រាប់យើងថា នៅលើផែនដីទាំងមូលដែលយើងរស់នៅសព្វថ្ងៃនេះ មិនមានកន្លែងណាដែលមិននៅក្រោមទឹកនោះទេ។ ការដែល ទឹកមាននៅលើផែនដីទាំងមូលនោះគឺជាភ័ស្តុតាងបញ្ជាក់ថា មានពេលមួយនៅក្នុងកាលកន្លងទៅមានការជំនុំជំរះដោយសារទឹកជន់លិចផែនដីជាប្រាកដមែន ប៉ុន្តែព្រះមិនអោយយើងដឹងច្រើនពីរឿងនេះទេ។ ព្រះជាម្ចាស់មានបន្ទូលអោយយើងដឹងល្មមគ្រប់គ្រាន់នឹងអោយយើងជឿព្រះអង្គបាន។

“ទ្រង់ហៅទីគោកនោះថាជាដី”។ តើព្រះជាម្ចាស់ទ្រង់នឹងយកដីនោះធ្វើអ្វី? បើតាមបទព្រះគម្ពីរ ព្រះជាម្ចាស់យកដីនេះដើម្បីធ្វើជាកន្លែងសម្រាប់មនុស្សលោកអោយធ្វើជាលំនៅដ្ឋានរបស់ខ្លួន។ មនុស្សមិនមែនជាសត្វទឹកទេ ទោះបីអ្នកដែលប្រកាន់យកទ្រឹស្តីនៃការវិវត្តន៍បានអះអាងថាមនុស្ស ប្រហែលជាកើតមកពីសត្វទឹក ឬ ស្លែ

ឬ សំរាមយ៉ាងណាក៏ដោយ។ មនុស្សមិនគួរមានគំនិតខុសឆ្គងបែបនេះសោះស្តីអំពីដើមកំណើតរបស់ខ្លួន។

> រួចព្រះទ្រង់មានបន្ទូលថា ចូរអោយដីដុះតិណជាតិឡើង គឺជាពួកស្មៅដែលមានគ្រាប់និងរុក្ខជាតិមានផ្លែតាមពូជ ដែលមានគ្រាប់ក្នុងផ្លែនោះនៅផែនដី នោះក៏មានដូច្នោះ (លោកុប្បត្តិ១០:១១)។

ព្រះជាម្ចាស់បានបង្កើតរុក្ខជាតិគ្រប់ប្រភេទ សម្រាប់ធ្វើជាអាហារដល់មនុស្សលោក។ បើតាមព្រះគម្ពីរ មុននឹងទឹកជំនន់ធំបាំនជន់លិចផែនដី មនុស្សសម័យនោះទទួលទានតិណជាតិជាអាហារតែប៉ុណ្ណោះ។ ការបង្កើតអោយមានរុក្ខជាតិបានធ្វើអោយមាន លក្ខណៈគ្រប់គ្រាន់និងចប់សព្វគ្រប់នៅថ្ងៃទី៣។

> **ដីក៏ដុះតិណជាតិទាំងឡាយឡើង គឺជាពួកស្មៅដែលមានគ្រាប់ តាមពូជ និងរុក្ខជាតិមានផ្លែតាមពូជដែរ ហើយមានគ្រាប់នៅក្នុង ផ្លែនោះឯង រួចទ្រង់ឃើញថាល្អ នោះក៏មានល្ងាចមានព្រឹកឡើង ជាថ្ងៃទី៣ (លោកុប្បត្តិ១:១២-១៣)។**

ថ្ងៃទី៤ ខែ ថ្ងៃ និងផ្កាយ

**បន្ទាប់មកព្រះទ្រង់មានបន្ទូលថា ចូរអោយមានតួពន្លឺនៅនាផ្ទៃមេឃដើម្បីនឹងញែកថ្ងៃចេញពីយប់ សម្រាប់ទុកជាទីសម្គាល់នៃ រដូវថ្ងៃនិងឆ្នាំ (លោកុប្បត្តិ ១០:១៤ )។**

គ្រង់នេះព្រះមិនបានបង្កើតថ្ងៃ ខែ និងផ្កាយក្នុងពេលនេះទេ។ ថ្ងៃនិងខែព្រះអង្គបានបង្កើតពីពេលមុនរួចមកហើយ ហើយពេលនេះទ្រង់គ្រាន់តែយករបស់ទាំង២នេះដាក់អោយត្រូវកន្លែងដែល វត្ថុទាំង២នោះត្រូវនៅតែប៉ុណ្ណោះ។

**ហើយសម្រាប់ជាពន្លឺនៅផ្ទៃមេឃ ដើម្បីបំភ្លឺមកផែនដីនោះក៏មាន ដូច្នោះទ្រង់ធ្វើពន្លឺធំជា២តួ១ដែលធំជាងនោះសម្រាប់បំភ្លឺក្នុង ពេលថ្ងៃ ហើយ១ដែលតូចជាងសម្រាប់បំភ្លឺ ក្នុងពេលយប់ក៏ធ្វើ អោយមានផ្កាយទាំងប៉ុន្មានដែរ (លោកុប្បត្តិ១:១៥-១៦ )។**

តួមួយធំជាងនោះបានទទួលខុសត្រូវបំភ្លឺលោកនៅពេលថ្ងៃ គឺតួនោះឯងដែលបញ្ចោញពន្លឺយ៉ាងអស្ចារ្យ។ ឯនៅពេលយប់លោកខែក៏បានបំពេញមុខងាររបស់ខ្លួន។ ខ្ញុំមិនដឹងថាលោកអ្នកមានចំណាប់អារម្មណ៍យ៉ាងណាទេ បើសិនជាលោកអ្នកអង្គុយនៅក្រោមពន្លឺខែនៅពេលយប់។ ខ្ញុំនិងប្រពន្ធខ្ញុំបានបង្កើតអនុស្សាវរីយ៍ល្អៗជាច្រើនយ៉ាងពេលយើងនិយាយគ្នាលេងនៅក្រោមពន្លឺខែ។ ពន្លឺខែមានឥទ្ធិពលណាស់នៅពេលយប់។

នៅក្នុងអត្ថបទដែលលោកអ្នកអានអម្បាញ់មិញនេះ មានកន្លែងមួយបានបើកសម្តែងថា"ទ្រង់ក៏ធ្វើអោយមានផ្កាយទាំងប៉ុន្មានដែរ"។ ការធ្វើអោយមានផ្កាយរាប់រយ

រាប់ពាន់ រាប់ម៉ឺន រាប់សែននេះ ជាកិច្ចការធំបំផុត ប៉ុន្តែចំពោះព្រះជាម្ចាស់វិញមិនមែនធំសម្រាប់ទ្រង់នោះឡើយ។

**ទ្រង់ដាក់តួពន្លឺទាំងនោះនៅផ្ទៃមេឃ សម្រាប់នឹងបំភ្លឺមកលើផែនដីអោយមានអំណាចនៅពេលថ្ងៃនិងពេលយប់ ហើយអោយញែកពន្លឺចេញពីងងឹតរួចទ្រង់ឃើញថាជាល្អ (លោកុប្បត្តិ១០:១៧-១៨ )។**

ត្រង់នេះខ្ញុំចង់អោយលោកអ្នកបងប្អូនកត់សម្គាល់ថា "ទ្រង់បានញែកពន្លឺចេញពីងងឹត"។

សព្វថ្ងៃនេះព្រះអង្គនៅតែបន្តធ្វើការនេះជារៀងរាល់ថ្ងៃផងដែរ។ មានអ្នកខ្លះ សួរថា "តើដូចម្តេចដែលហៅថាខុសនិងត្រូវ?" ព្រះបានគូសបន្ទាត់ចន្លោះធាតុទាំងពីរនេះច្បាស់លាស់ណាស់។ តើដូចម្តេចដែលហៅថាត្រូវ? ចម្លើយឆ្លើយថា ដែលហៅថាត្រូវគឺអ្វីៗដែលព្រះជាម្ចាស់មានបន្ទូលថាត្រូវ។ ព្រះជាម្ចាស់បានធ្វើច្បាប់សម្រាប់រស់នៅមានច្រើនបែបច្រើនយ៉ាងណាស់។ ទ្រង់បានញែកពន្លឺចេញពីងងឹតគឺច្បាប់នេះហើយដែលសម្តែងពីធាតុខុសនិងត្រូវ។ ព្រះអង្គបានធ្វើការញែកធាតុទាំងពីរនេះអោយដាច់ពី គ្នា ហើយទ្រង់កំពុងធ្វើការនោះសព្វថ្ងៃនេះ។

**នោះក៏មានល្ងាចមានព្រឹកឡើង ជាថ្ងៃទី៤ (លោកុប្បត្តិ១០:១៩ )។**

## ថ្ងៃទី៥ ជីវិតសត្វ

**បន្ទាប់មកព្រះទ្រង់មានបន្ទូលថា ចូរអោយមានមច្ឆាជាតិរវើកនៅក្នុងទឹកជាបរិបូរ និងបក្សីជាតិហើរ លើដីនៅនាអាកាស (លោកុប្បត្តិ១០:២០ )។**

យើងឃើញមានព្រំដែនខ្លះស្តីពីការរីកសាយពូជសត្វនានា។ ត្រង់នេះមិនមែនមានន័យថាវត្ថុធាតុគ្រប់យ៉ាងកើតពីធាតុតែមួយនោះទេ។ ព្រះជាម្ចាស់បានបង្កើតសត្វមួយបែបមករួចមានការសាយពូជសត្វមួយបែបនោះបន្តទៅទៀត។ ព្រះជាម្ចាស់មានបន្ទូលថា"ចូរអោយមានមច្ឆាជាតិរវើក នៅក្នុងទឹកជាបរិបូរ"រួចមកខបន្ទាប់បានថែងថា"តាមពូជ"។ ពាក្យនេះនៅក្នុងភាសាហេព្រើរគេនិយាយថា "ហ្មីឡឹម" ដែលមានន័យថា ខ្សែស្រឡាយពីឈាមជ័រដដែល។ ឧទាហរណ៍ដូចជាសត្វសេះមិនមែនមានសេះតែម៉្យាងនោះទេ គឺមានសត្វសេះដែលជាគ្រួសាររបស់វាជាច្រើនថែមទៀត។ ព្រះបានបង្កើតសត្វមួយប្រភេទនេះមក រួចហើយមានការសាយពូជតាមប្រភេទរបស់សត្វនោះ។ បើនិយាយពីពូជនេះមានពូជក្លាយនិងមានពូជផុតដែរ ។

**ទ្រង់ក៏បង្កើតអស់ទាំងសត្វសម្បើមៗ និងជិវិតទាំងឡាយដែលកំ រើកដែលកើតមានវិនវណ្ណ៍នៅក្នុងទឹកតាមពូជ ហើយអស់ទាំងសត្វស្លាបតាមពូជដែរ រួចទ្រង់ឃើញថាល្អ (លោកុប្បត្តិ១០:២១ )។**

"រួចទ្រង់ឃើញថាល្អ" សូមលោកអ្នកបងប្អូនមេត្តាកត់ចំណាំចំណុចត្រង់នេះកាលណាព្រះជាម្ចាស់ធ្វើអ្វីមួយមកហើយ ការនោះពិតជាល្អប្រាកដ។

**ទ្រង់ក៏ប្រទានពរដល់សត្វទាំងឡាយនោះ ហើយមានបន្ទូលថា ចូរបង្កើតកូនអោយចម្រើនជាច្រើនឡើង អោយមានពេញពាសនៅក្នុងទឹកសមុទ្រ ហើយអោយសត្វស្លាបចម្រើនឡើងនៅផែនដីដែរ (លោកុប្បត្តិ១០:២២ )។**

កាលពីមុនខ្ញុំបានស្រង់ពាក្យសម្ដីរបស់អ្នកវិទ្យាសាស្ត្រមួយរូបថា បើអនុញ្ញាតអោយសិស្សរៀនប្រធានបទកំណើតលោកីយ៍ ត្រូវអោយរៀនទ្រឹស្ដីកំណើតរបស់សត្វកុកកវែងជាមុនសិន។ លោកអ្នកបងប្អូនអើយ សូមជឿខ្ញុំចុះថា ព្រះគម្ពីរមិនគាំទ្រទ្រឹស្ដីកំណើតសត្វកុកកវែងនេះទេ។ បើលោកអ្នកអានព្រះគម្ពីរអោយបាន ល្អិតល្អន់ ហើយស្វែងយល់អោយបានស៊ីជំរៅនោះ លោកអ្នកនឹងឃើញសត្វគ្រប់ប្រភេទដែលបានកើតតាមពូជរបស់វា។ ឯមនុស្សលោកក៏ដូចគ្នាដែរ។ យើងមិនដែលឃើញមានដើមឈើមានផ្លែអាចបង្កើតកូនបានជាមនុស្សនោះឡើយ។ ចំណែកឯសត្វកុកកវែងមិនដែលបង្កើតកូនបានជាមនុស្សដែរ។

**នោះក៏មានល្ងាច មានព្រឹកឡើង ជាថ្ងៃទី៥ (លោកុប្បត្តិ១០:២៣ )។**

## ថ្ងៃទី៦ គ្រប់ជីវិតត្រូវបន្តពូជ

**បន្ទាប់មកព្រះទ្រង់មានបន្ទូលថា ចូរអោយមានចតុប្បាទជាតិកើតមកនៅដីគោកតាមពូជគឺជាសត្វស្រុក សត្វលូនវារនិងសត្វ**

**ព្រៃនៅផែនដីតាមពូជនោះក៏មានដូច្នោះ ទ្រង់ក៏ធ្វើសត្វព្រៃនៅផែនដីតាមពូជសត្វស្រុកតាមពូជ ហើយគ្រប់ទាំងសត្វដែលលូនវារនៅដីគោក តាមពូជដែរ រួចទ្រង់ឃើញថាល្អ (លោកុប្បត្តិ១០:២៤-២៥ )។**

សូមកត់ចំណាំពាក្យ "តាមពូជ" នេះមានន័យថាតាមជាតិ កំណើត។ មកទល់វេលានេះយើងឃើញថាព្រះជាម្ចាស់បានញែកជីវិតរុក្ខជាតិសត្វ អោយដាច់ចេញពីជីវិតមនុស្សលោក។ ទ្រង់មានបន្ទូលថា "ចូរយើងធ្វើមនុស្សអោយដូចយើង"។ ភារៈធំចុងក្រោយបង្អស់នេះមានសារៈសំខាន់សម្រាប់យើងគ្រប់រូប ពោលគឺបុគ្គលមួយរូបនេះហើយដែលជាជីទួត ជីលួត ជីលា។ល។ ...របស់យើង រាល់គ្នា។ ត្រង់ចំណុចនេះមានន័យថា លោកអ្នកនិងខ្ញុំជាបងប្អូនរួមឈាមរួមសាច់ ជាមួយគ្នា ទោះបីជាបងប្អូនខ្លះមិនមែនជាបងប្អូនរួមផ្ទៃជាមួយនឹងខ្ញុំក៏ដោយ។ មនុស្សជាតិគ្រប់សាសន៍កើតមកពីគ្រួសារតែមួយប៉ុណ្ណោះ។